ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញៈ ថ្ងៃទី ១២ ខែមករា ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អមដោយឯកឧត្តម **ជុំ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមលោកស្រីអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសំដែងអំណរសាទរជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំត្រីមាសទី៤និងប្រចាំឆ្នាំ២០១៤និងជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៥។



ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានរាយការណ៍អំពីស្ថានភាពចំណូលពន្ធដារ មានដូចជា៖ ក្នុងខែធ្នូ ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៨១៤ ៣១៥ លានរៀល (គិតជាដុល្លារ ១០៣,៥៨ លានដុល្លារ) ដែលចំណូលនេះមានការកើនឡើងជាងខែវិច្ឆិកា ឆ្នាំ២០១៤ ស្មើនឹង ៣៦,៥៣% ។ ប្រសិនបើប្រៀប

ធៀបទៅនឹងចំណូលពន្ធសម្រាប់ខែធ្នូ ឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិ ប្រចាំខែធ្នូ ឆ្នាំ២០១៤ នេះ មានការកើនឡើង ស្មើនឹង ១,៧៩%។

សម្រាប់ឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធផ្ទៃក្នុងបានចំនួន ៤ ២៥១ ១៦១ លានរៀល (គិតជាដុល្លារ ១ ០៦២,៧៩ លានដុល្លារ)ស្មើនឹង **១០៦,៩៤%** នៃផែនការច្បាប់ ក្នុងនោះ ថវិកាថ្នាក់ជាតិបានចំនួនស្មើនឹង ១០៦,៩០% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិបានចំនួន ស្មើនឹង ១០៧,០%។ ប្រសិនបើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិ សម្រាប់ឆ្នាំ២០១៤ នេះ **កើនឡើងចំនួន** ស្មើនឹង **១៧,៩៣%**។



ក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៣ និងឆ្នាំ២០១៤ ឃើញថា ក៏មានការកើនឡើងនូវចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ២៩,៦% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ២៣,៩% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៨,៧% និង អាករពិសេសមានការកើនឡើងប្រមាណ ១៣,៣% ។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១៣ និងឆ្នាំ២០១៤ ចំណូលពន្ធតាមសកម្មភាពអាជីវកម្មមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ១៤,៩% សេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២២,៨% ទូរគមនាគមន៍កើនឡើងប្រមាណ ២,៣% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៤៤,៣% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ២៩,២% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៤៨,១% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ១០,៨% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤៥,៥% ផលិតថ្នាំជក់កើនឡើងប្រមាណ ១៤,៥% អាជីវកម្មអចលនទ្រព្យកើនឡើងប្រមាណ ១២៨,២% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ១៥,០% លក់ភេសជ្ជៈកើនឡើងប្រមាណ ៣៨,១% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៣៨,៥% ផលិតម្ហូបអាហារកើនឡើងប្រមាណ ៧៥,១% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៤៥,៩% លក់ផលិតផលឱសថកើនឡើងប្រមាណ ១៤៥,២% និងលក់គ្រឿងសំណង់កើនឡើងប្រមាណ ១.៤១២,៤%។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-ពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំឆ្នាំ២០១៤របស់នាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៥ ឲ្យបានគ្រប់តាមផែនការច្បាប់។ II- វឌ្ឍនភាពនៃការចាត់អាជីវកម្មដ្ឋានជាប់ពន្ធតាមរបបម៉ៅការទៅរបបស្វ័យប្រកាស ការសិក្សារៀបចំបញ្ជីការគណនេយ្យពន្ធដារសម្រាប់អ្នកជាប់ពន្ធតាមស្តង់ដារ ពិនិត្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ ការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤និងពន្ធដីធ្លីមិនបានប្រើប្រាស់ ការបង់ពន្ធលើប្រាក់បៀវត្ស។ III-ពន្យល់ណែនាំ

និងពិភាក្សាការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មី និងការធ្វើបច្ចុប្បន្នភាពសហគ្រាស IV-ពិភាក្សាអំពីវឌ្ឍនភាពនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលបានអនុវត្តកន្លងមក។ V-ពិនិត្យការរៀបចំមន្ត្រីរាជការពន្ធដារជាមន្ត្រីនគបាលយុត្តិធម៌VI-ការចុះពិនិត្យមើលជាក់ស្តែងដល់កន្លែងធ្វើការងាររបស់មន្ត្រីពន្ធដារនៅតាមការិយាល័យនីមួយៗនៅថ្នាក់កណ្តាលនៃអគ្គនាយកដ្ឋានពន្ធដារ និង V-បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឱ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនោះ ជាទិសដៅអនុវត្តបន្ត អគ្គនាយកដ្ឋានពន្ធដារនឹងត្រូវយកយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ យកធ្វើជាត្រីវិស័យបង្ហាញផ្លូវក្នុងការប្រមូលចំណូលសម្រាប់ឆ្នាំ២០១៥ ក៏ដូចជាសម្រាប់បណ្តាឆ្នាំខាងមុខ ដោយផ្តោតលើចំណុចសំខាន់ៗមានដូចជា÷ I-ការពង្រឹងរដ្ឋបាលចំណូលពន្ធដារ រួមមាន ១-ការពង្រឹងមុខងារប្រតិបត្តិការស្នូល (ការចុះបញ្ជីអ្នកជាប់ពន្ធ ការផ្តល់សេវាអ្នកជាប់ពន្ធ ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្មពន្ធ ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា) ២-ការពង្រឹងមុខងារគាំទ្រ (ការពង្រឹងការគ្រប់គ្រងនិងរចនាសម្ព័ន្ធ ការគ្រប់គ្រងធនធានមនុស្ស និង បច្ចេកវិទ្យាព័ត៌មាន (IT))។ II- កំណែទម្រង់គោលនយោបាយពន្ធ រួមមាន ១- អាករពិសេសលើទំនិញ និងសេវាមួយចំនួន ២- អាករលើតម្លៃបន្ថែម ៣- របបម៉ៅការ ៤-ពិនិត្យឡើងវិញរបបលើកទឹកចិត្តផ្នែកពន្ធដល់គម្រោងវិនិយោគ ៥- កិច្ចព្រមព្រៀងពន្ធអន្តរជាតិ ៦-ពន្ធលើអចលនទ្រព្យ ៧- ពន្ធលើចំណូលរូបវន្តបុគ្គល ៨-ពន្ធលើប្រតិបត្តិការប្រេងកាតនិងធនធានរ៉ែ និង៩- ការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ។

ជាកិច្ចបញ្ចប់ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានវាយតម្លៃខ្ពស់និងកោតសរសើរនិងគាំទ្រចំពោះការខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធដារ ដែលមានការកើនឡើងលើសផែនការគួរជាទីពេញចិត្តបាន និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់ឯកឧត្តម អស់លោកជាថ្នាក់ដឹកនាំប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ ខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឱ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឱ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ និងអនុវត្តទៅតាមស្មារតីចំនួន ០៤ គឺ ការធ្វើការងារជាក្រុម ការប្រកាន់ភ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារ សូមកុំមើលរំលងនូវកំហុសខ្លួនឯង និងស្មារតីបុរេសកម្ម ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

